ចេញផ្សាយលេខពិសេស 2006

# CONNECT



## តើអ្នកជាបុរសបែបណា?

មូលដ្ឋានគ្រឹះបុរស...
ចំណោរចិត្តបុរសលើវិស័យកីឡា
បទពិសោធន៍លើវិថីស្នេហ៍
ទម្លាប់បុរសដែលជក់ជាប់នឹងផ្នែកបច្ចេកវិទ្យា
ស្ទីល និងភាពលេចធ្លោនៃបុរស

រឹតតែច្បាស់
cellcard
www.cellcard.com.kh

## តើអ្នកជាបុរសបែបណា ?






ការស្រឡាញ់ចូលចិត្ត ជាពិសេសទំលាប់ដែលធ្វើប្រចាំថ្ងៃរបស់បុរសម្នាក់ៗ ដែលបង្ហាញឲ្យឃើញ គឺជាចំនុចសំខាន់ និងសំរាប់សំគាល់នូវចរិតលក្ខណៈ និងភាពខុសគ្នារបស់បុរស ឧទាហរណ៍ដូចជាបុរសខ្លះគាត់ចូលចិត្ត ជីវិតបែបរ៉ូមែនទិក ខ្លះបែបវិទ្យាសាស្ត្រពាក់ព័ន្ធនឹងបច្ចេកវិទ្យា ខ្លះលើមុខជំនួញ ខ្លះទៀតកីឡា ហើយខ្លះទៀតនោះនិយម លេងស្ទីលប្លែកៗថ្មីៗ ។ល។និង។ល។ គឺពុំមានលក្ខណៈដូចគ្នានោះទេ !

ចុះចំណែកអ្នកវិញ ជាបុរសបែបណា ? បើមិនទាន់ដឹងទេ សូមសាកល្បងវាយតម្លៃឲ្យខ្លួនឯងលំមើល...!



## MR. TECHIE

### ទម្លាប់បុរសដែលជក់ជាប់នឹងផ្នែកបច្ចេកវិទ្យា

ក្រោយពីបានជួបសម្ភាសជាមួយលោក តូ សាលី និស្សិតសកលវិទ្យាល័យ ន័រតុន ឆ្នាំទី៣ ផ្នែកព័ត៌មានវិទ្យា និងជាបុរសម្នាក់មានអារម្មណ៍ផ្តោតជាប់ក្នុងចិត្តយ៉ាងខ្លាំងផ្នែកបច្ចេកវិទ្យា ទើបបានស្វែងយល់បន្ថែមថា អារម្មណ៍របស់បុរសមានលក្ខណៈខុសគ្នាអារម្មណ៍មួយដែលជក់ជាប់ក្នុងចិត្ត មានន័យស៊ីជំរៅ និងចងចាំអស់មួយជីវិត ខ្លាំងជាងអារម្មណ៍ដែលគ្រាន់តែចូលចិត្ត និងចាប់អារម្មណ៍ ។ គាត់បានបង្ហើបប្រាប់ពីអារម្មណ៍ផ្ទាល់ខ្លួនឲ្យដឹងថា៖ គាត់មានអារម្មណ៍ មួយខុសប្លែកពីគេនៅពេលចង់ដឹង ចង់ចេះអ្វីមួយ គឺប្រើអារម្មណ៍ផ្តោតទៅយ៉ាងខ្លាំង ជាពិសេសគឺផ្នែកបច្ចេកវិទ្យា គ្រប់ពេលគាត់តែងតែតាមដានព័ត៌មានថ្មីដែលពាក់ព័ន្ធបច្ចេកវិទ្យា មិនថាទស្សនាវដ្តី កាសែត ទូរទស្សន៍ ឬក៏អ៊ិនធើណិតនោះទេ អារម្មណ៍នេះបានក្លាយទៅជាទំលាប់មួយរបស់គាត់ ហើយក៏ជាទំលាប់ដ៏ល្អមែនទែនសំរាប់គាត់ ព្រោះយ៉ាងហោចណាស់ក៏អាចធ្វើឲ្យគាត់បានដឹងនូវបច្ចេកវិទ្យាទំនើបទាន់សម័យ ជាពិសេសអាចធ្វើឲ្យគាត់ជាមនុស្សដែលទាន់សម័យដើរទាន់សង្គម ។



## MR. ROMANTIC

### បទពិសោធន៍លើវិថីស្នេហ៍

យុវវ័យគ្រប់រូបពេលធំពេញវ័យត្រូវតែស្គាល់ ត្រូវតែភ្លក់គ្រប់រសជាតិស្នេហ៍ នេះជាក្រឹត្យក្រមរបស់ធម្មជាតិ គ្មាននរណាម្នាក់អាចជៀសផុត និងអាចដឹងមុនបានទេ បើអាចដឹងមុនបាន គឺដឹងបានតាមបែបសម្មិដ្ឋាន តាមបទពិសោធន៍ផ្សេងៗរបស់យុវវ័យជំនាន់មុនបន្សល់ទុកឲ្យ ជាក់ស្តែងដូចជាចំនុចខាងក្រោមនេះគឺជាបទពិសោធន៍ល្អៗរបស់ លោក គ្រុយ ប៉េងអ៊ី បុគ្គលិកបំរើការសណ្ឋាគារភ្នំពេញ ធ្លាប់បានឆ្លងកាត់កន្លងមក ៖ ការស្វែងយល់ពីអ្នកដែលយើងស្រឡាញ់ឲ្យបានច្រើន ព្យាយាមបង្ហាញនូវទឹកចិត្តស្មោះ និងការព្រួយបារម្ភឲ្យគេឃើញ ។ បង្កើនរសជាតិស្នេហ៍បន្ថែម ដោយទៅញ៉ាំអាហារនៅភោជនីយដ្ឋានបែបរ៉ូមែនទិក ឬនៅតាមរមណីដ្ឋានកំសាន្តផ្សេងៗទៀតដែលអាចជួយធ្វើឲ្យអារម្មណ៍ស្នេហ៍តូចត្របាញ់ចូលគ្នា ទិញកាដូអនុស្សាវរីយ៍ជូនគេនៅថ្ងៃខួបកំណើត ទូរស័ព្ទទំនាក់ទំនងជាមួយគេឲ្យបានជាប្រចាំ ទោះតិចក្តីច្រើនក្តីទាំងអស់នេះគឺសុទ្ធតែជារូបមន្ត និងបទពិសោធន៍ដែលអាចប្រែក្លាយជាចំណងរឹតបន្តឹងស្នេហាឲ្យមានភាពល្អកញ្ចើន និង យូរអង្វែង ។



## MR. STYLISH

### ស្ទីល និងភាពលេចធ្លោនៃបុរស

អាចថាមកពីកាលៈទេសៈ សង្គម ឬតម្រូវការផ្សេងទៀតក៏ថាបាន ដែលជំរុញឲ្យបុរសៗប្រាថ្នាចង់បាននូវភាពលេចធ្លោ និងភាពល្បីល្បាញក្នុងជីវិត ។ ចុះធ្វើដូចម្តេចទើបអាចទទួលបាននូវភាពវិសេសវិសាលនេះ? ធ្វើខ្លួនឲ្យក្លាយជាបុរសម្នាក់ដែលស្ទីល ឡូយ សង្ហា ដូចជាប្តូរស្ទីលប្លែកៗថ្មីៗ ដោយលួចយកនូវគំនិតល្អៗពីខាងក្រៅយកមកច្នៃប្រឌិតជាស្ទីលផ្ទាល់ខ្លួន ឲ្យស្របទៅតាមពេលវេលា និងកម្មវិធីនីមួយៗ ។ ចូលរួមក្នុងកម្មវិធីត្រូវរៀបឫកពា ស្លៀកពាក់របៀបណាទើបអាចចូលចុះក្នុងចំណោម ទាក់ទាញចំណាប់អារម្មណ៍ពីមនុស្សម្នាដែលជាអ្នកចាំផាក់ពិន្ទុ ចាំផ្តល់នូវភាពលេចធ្លោ ។ កុំប្រឡូកឲ្យសោះ បុរសដែលស្ទីល និងមិនមែនស្ទីល ! ដូចរូបខ្ញុំអញ្ចឹង (ឈ្មោះ លី ស៊ីនែល អាយុ ២២ ឆ្នាំ សិស្សនៅសកលវិទ្យាល័យបញ្ញាសាស្ត្រ) មើលមកសាមញ្ញ រួសរាយ រាក់ទាក់ ទៅទីណាក៏គេរាប់អាន ទទួលស្គាល់ សំលៀកបំពាក់ និងការតុបតែងខ្លួនធម្មតាមិនអស្ចារ្យណាស់ណាំពេក ម៉ាល្មមអាចមើលមកចូលភ្នែក ហ៊ានសម្បើងផងខ្លួន ចូលចុះក្នុងសង្គម ។







## MR. BUSINESSMAN

### មូលដ្ឋានគ្រឹះបុរសដែលទទួលបានជោគជ័យលើមុខជំនួញ

ទេពកោសល្យពីកំណើតផ្សំផ្គុំជាមួយបទពិសោធន៍ការងារ និងការសិក្សាបន្ថែមពីមជ្ឈដ្ឋានខាងក្រៅ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំនាំទៅរកភាពជោគជ័យ ។ ឈរលើកត្តាសំខាន់ៗខាងលើនេះ លោក ស្រៀង លីណារ៉ូ អាយុ ២៩ ឆ្នាំ ម្ចាស់ហាងលក់ស៊ីឌី ហ៊ីប ហប នៅផ្សារទំនើបសុរិយា បានបោះជំហានជោគជ័យមួយកំរិតបន្ថែមទៀត ជាមួយនឹងការបើកមុខជំនួញថ្មី គឺហាងលក់សំលៀកបំពាក់ដ៏ទំនើបទាន់សម័យ ដែលកំពុងទទួលបាននូវការពេញនិយម ។ គាត់បានបង្ហើបពីភាពជោគជ័យរបស់គាត់ឲ្យដឹងថា ៖ ក្លាយជាអ្នកជំនួញម្នាក់ជោគជ័យ ត្រូវចេះក្តោបយកឱកាសល្អៗ គិតឲ្យបានគ្រប់ជ្រុងជ្រោយ ត្រូវមានទំនុកចិត្ត និងភាពជឿជាក់លើខ្លួនឯង ទន្ទឹមនឹងនោះ ត្រូវចេះគ្រប់គ្រង និងមានការទទួលខុសត្រូវខ្ពស់ ជាពិសេសត្រូវចេះសិក្សាវិភាគលើទីផ្សា និងរៀបចំគំរោងឯកសារ ។







## MR. SPORTY

### ចំនោរចិត្តបុរសលើវិស័យកីឡា

សុខភាពគឺជាបញ្ហាចំបង បើចង់ឲ្យមានសុខភាពល្អ គឺត្រូវហាត់កីឡា !
គិតដល់ចំនុចនេះ លោក សេង ពិសី បុគ្គលិកបំរើការសណ្ឋាគារភ្នំពេញ បានផ្តល់នូវយោបល់ខ្លះៗថា៖ កីឡាមិនត្រឹមតែនាំមកនូវសុខភាព និងភាពជោគជ័យប៉ុណ្ណោះទេ កីឡាក៏អាចជួយយើងឲ្យជៀសផុត ពីរឿងអបាយមុខ និងជំងឺផ្កាត់ផ្សេងៗទៀតផងដែរ...ហាត់កីឡាមានរឿងអ្វីត្រូវពិបាក សប្បាយហើយមានសុខភាពល្អ ជាពិសេសថាមិនត្រូវមើលមិនឃើញអាចក្លាយជាកីឡាករជំរើសជាតិដ៏ឆ្នើមមួយរូបផងក៏មិនដឹង...! ។ គាត់បន្ថែមទៀតថា ៖ ខ្ញុំមាននិស្ស័យចូលចិត្តវិស័យកីឡាតាំងពីអាយុ ៨ ឆ្នាំមកម្ល៉េះ ជាពិសេសកីឡាបាល់ទាត់ ដែលខ្ញុំតែងតែប្រកួតកំសាន្តជាមួយមិត្តភក្តិនៅពេលសំរាកពីការសិក្សា ប៉ុន្តែការប្រកួតនោះមិនមានលក្ខណៈជាផ្លូវការនោះទេគ្រាន់តែប្រកួតជាលក្ខណៈមិត្តភាពប៉ុណ្ណោះ រហូតដល់ខ្ញុំចូលសិក្សានៅវិទ្យាល័យ ខ្ញុំបានទទួលការហ្វឹកហាត់ត្រឹមត្រូវ ទើបមានឱកាសចូលរួមប្រកួតតំណាងឲ្យសាលាទាំងមូល ។ ហើយសព្វថ្ងៃនេះ បើទោះជាចេញធ្វើការហើយក្តីក៏ខ្ញុំនូវតែឆ្លៀតពេលលេងដែរ ព្រោះខ្ញុំយល់ថាវាអាចជួយធ្វើឲ្យ ជីវិតយើងស្រស់ថ្លា ។

